

# សូមរក្សាសុវត្ថិភាព! ការប្រើប្រាស់ទូរសព្ទចល័តពេលបើកបរ៖

## អ្វីដែលអ្នកត្រូវដឹង

## គន្លឹះ

1. **សូមរៀបចំអ្វីៗឱ្យរួចរាល់ មុនពេលចាប់ផ្តើមបើកបរ។** បញ្ចូលទិសដៅ GPS ចាប់ផ្តើមបញ្ជីចម្រៀង ឬផតខាស (podcast) ហើយកំណត់ទូរសព្ទរបស់អ្នកទៅជា “Do Not Disturb” មុនពេលចេញដំណើរ។
2. **សូមផ្តោតអារម្មណ៍លើការបើកបរ ទោះបីប្រើមុខងារមិនបាច់កាន់ទូរសព្ទក៏ដោយ។** កំណត់ការហៅទូរសព្ទ ជៀសវាងការសន្ទនាយូរ ឬស៊ីជម្រៅ ហើយផ្តោតលើការបើកបរ ជាពិសេសនៅពេលចរាចរណ៍មមាញឹក ឬអាកាសធាតុមិនល្អ។
3. **សូមឈប់រថយន្តនៅកន្លែងមានសុវត្ថិភាព ប្រសិនបើត្រូវការសន្ទនាសំខាន់។** ប្រសិនបើការហៅទូរសព្ទត្រូវការការផ្តោតអារម្មណ៍ សូមស្វែងរកកន្លែងមានសុវត្ថិភាពដើម្បីឈប់រថយន្តសិន មុននឹងបន្តការសន្ទនា។
4. **សូមឱ្យអ្នកដំណើរជួយប្រើប្រាស់ទូរសព្ទជំនួសអ្នក។** ប្រសិនបើអ្នកត្រូវការជំនួយពេលបើកបរ សូមកំណត់អ្នកដំណើរម្នាក់ឱ្យធ្វើជា “អ្នកជំនួយការបើកបរ”។
5. **ធ្វើជាគំរូល្អសម្រាប់អ្នកដទៃ។** តែងតែអនុវត្តការប្រើប្រាស់ទូរសព្ទប្រកបដោយសុវត្ថិភាពនៅក្នុងរថយន្ត ព្រោះវាជួយលើកកម្ពស់ការយល់ដឹងអំពីសុវត្ថិភាពសម្រាប់មនុស្សគ្រប់គ្នា។

## សូមរក្សាសុវត្ថិភាព កុំឱ្យទូរសព្ទបង្អាក់ការផ្តោតអារម្មណ៍!

អ្នកអាចរងរបួស ឬបាត់បង់ជីវិត ប្រសិនបើអ្នកបណ្តោយឱ្យទូរសព្ទចល័តបង្អាក់ការផ្តោតអារម្មណ៍របស់អ្នកពេលកំពុងបើកបរ។ ស្ថិតិថ្មីៗបង្ហាញថា មានមនុស្សប្រមាណ 3,000 នាក់បានស្លាប់ជារៀងរាល់ឆ្នាំ ដោយសារគ្រោះថ្នាក់ចរាចរណ៍ដែលពាក់ព័ន្ធនឹងអ្នកបើកបរខ្វះការផ្តោតអារម្មណ៍។

## សូមផ្តោតលើផ្លូវ មិនមែនលើទូរសព្ទរបស់អ្នកទេ។

ការប្រើប្រាស់ទូរសព្ទចល័តពេលកំពុងបើកបរ គឺមានគ្រោះថ្នាក់។ ការផ្ញើសារពេលកំពុងបើកបរ អាចធ្វើឱ្យប្រតិកម្មរបស់អ្នកយឺត មិនខុសពីអ្នកបើកបរដែលមានកម្រិតជាតិអាល់កុលក្នុងឈាម (BAC) 0.08 នោះទេ។ វាមានគ្រោះថ្នាក់មិនខុសពីការបើកបរក្នុងស្ថានភាពស្រវឹងនោះទេ! ការផ្ញើសារពេលបើកបរ ធ្វើឱ្យអ្នកបង្វែរភ្នែកចេញពីផ្លូវ ជាមធ្យមប្រហែល 5 វិនាទី។ រយៈពេលនេះ គ្រប់គ្រាន់ឱ្យរថយន្តរបស់អ្នកធ្វើដំណើរបានប្រហែលប្រវែងទីលានបាល់ទាត់មួយ នៅល្បឿន 55 ម៉ាយក្នុងមួយម៉ោង។ គ្រោះថ្នាក់ចរាចរណ៍ភាគច្រើនកើតឡើងក្នុងស្ថានភាពដែលអ្នកបើកបរមានពេលតិចជាង 3 វិនាទីដើម្បីប្រតិកម្ម។

## បើកបរដោយប្រុងប្រយ័ត្ន។ សូមរក្សាសុវត្ថិភាព។ កុំប្រើទូរសព្ទពេលកំពុងបើកបរ។

សម្រាប់ព័ត៌មានបន្ថែម សូមចូលទៅកាន់គេហទំព័ររបស់ California Highway Patrol និងCalifornia Office of Traffic Safety។ សម្រាប់រឿងពិតដែលទាក់ទងនឹងការប្រើទូរសព្ទពេលបើកបរ សូមមើល www.nhtsa.gov/campaign/distracted-driving។



បន្តទៅខាងក្រោយ

California Public Utilities Commission
505 Van Ness Ave.
San Francisco, CA 94102
800-848-5580 (ឥតគិតថ្លៃ)
cpuc.ca.gov

TEAM PROGRAM
TELECOMMUNICATIONS EDUCATION AND ASSISTANCE IN MULTIPLE LANGUAGES
A PROGRAM OF THE CALIFORNIA PUBLIC UTILITIES COMMISSION



## ការបើកបរដោយខ្វះការផ្ដោតអារម្មណ៍ គឺជាអ្វីក៏ដោយដែលធ្វើឱ្យភ្នែក ដៃ ឬចិត្តរបស់អ្នកបែកអារម្មណ៍ពីការបើកបរ។

ការប្រើប្រាស់ទូរសព្ទចល័តពេលកំពុងបើកបរ គឺខុសនឹងច្បាប់៖ ការចុច ឬកាន់ទូរសព្ទពេលកំពុងបើកបរ គឺខុសច្បាប់ ទោះបីគ្រាន់តែមើល GPS ឬប្តូរចម្រៀងក៏ដោយ។ សម្រាប់អ្នកដែលមានអាយុក្រោម 18 ឆ្នាំ ការនិយាយទូរសព្ទចល័តពេលកំពុងបើកបរ គឺខុសនឹងច្បាប់។ មនុស្សពេញវ័យអាចនិយាយទូរសព្ទចល័តបាន ប៉ុន្តែមិនត្រូវបានអនុញ្ញាតឱ្យកាន់ទូរសព្ទពេលកំពុងបើកបរឡើយ។ មនុស្សគ្រប់រូបអាចប្រើទូរសព្ទចល័ត ដើម្បីធ្វើការហៅទូរសព្ទក្នុងគ្រាអាសន្នបាន។ ទោះជាយ៉ាងណាក៏ដោយ គួរឈប់រថយន្តនៅកន្លែងមានសុវត្ថិភាពជាមុនសិន។ ការផាកពិន័យចំពោះការផ្ញើសារពេលកំពុងបើកបរ ឬការមិនប្រើឧបករណ៍មិនបាច់កាន់ទូរសព្ទ អាចចាប់ផ្តើមពីប្រហែល U$160 ហើយអាចកើនឡើង ប្រសិនបើអ្នកប្រព្រឹត្តល្មើសម្តងទៀត។

**ព័ត៌មានទំនាក់ទំនងរបស់ CBO៖**

California Public Utilities Commission

**ព័ត៌មានអប់រំ និងជំនួយផ្នែកទូរគមនាគមន៍ជាភាសាច្រើន**

**កម្មវិធី (TEAM)**

www.cpuc.ca.gov/team-and-changes

teamandchanges@cpuc.ca.gov

ប្រសិនបើអ្នកមិនអាចដោះស្រាយការជំទាស់របស់អ្នកជាមួយក្រុមហ៊ុនផ្តល់សេវាកម្មបានទេ សូមទាក់ទង TEAM CBO របស់អ្នក។